# វគ្គទី២

## ការល្បងដណ្តើមយកវិញ

~១~

### ការល្បងដណ្តើមយកវិញ រៀបចំឡើងដោយក្សត្រខ្មែរ

នៅឆ្នាំ១៧៣៨ គឺក្នុងរយៈពេល២ឆ្នាំក្រោយពីឈ្មោះ ម៉ាក់គុយ ស្លាប់ទៅ ព្រះបាទធម្មោរាជាអង្គសូ(១៧៣៨-១៧៤៧) ទ្រង់ឆ្លៀតឱកាសខ្មែរនិងយួនទាស់គ្នា បញ្ជូនទ័ពខ្មែរមួយចំនួនទៅច្បាំងដេញមេទ័ពសត្រូវឈ្មោះ ម៉ាក់តុង ចេញពីខេត្តពាម (ហាទៀង)។ ប៉ុន្តែទ័ពរបស់ព្រះធម្មោរាជាអង្គសូទទួលបរាជ័យ ហើយត្រូវបង្ខំចិត្តដកថយមកវិញ ដោយហេតុក្រុងពាម ត្រូវទ័ពយួននិងចិនការពារមុតមាំខ្លាំងពេក (អញ្ជើញអានសៀវភៅ អាដេម៉ារ ឡឺក្លែរ A. Leclère ទំព័រ៣៧៨) ។ នៅឆ្នាំ១៧៣៨ដដែល ឧកញ៉ានិរិន្ទគុក ជាចៅហ្វាយស្រុកៗបាសាក់ក៏បានលើកទ័ពច្បាំងដេញយួនអណ្តាមចេញពីតំបន់នេះដែរ ។

ដល់មកឆ្នាំ១៧៧៦ គឺក្នុងឱកាសដែលពួកតៃសឺនបះបោរប្រឆាំងនឹងស្តេចក្រុងវេ ខ្មែរនៅកម្ពុជាក្រោម (ឬកូសាំងស៊ីន) បានក្រោកឡើងវាយកំចាត់យួនដែរ ។ ក្នុងពេលនោះ ព្រះបាទរាមរាជា (ព្រះអង្គនន់) បានបដិសេធមិនព្រមលើកទ័ពទៅជួយស្តេចង្វៀងអាន (យ៉ាឡុង) តាមសេចក្តីសុំនៃស្តេចនេះសោះឡើយ ។ ស្តេចយួនបានលើកទ័ពមកវាយខ្មែរភ្លាម តែត្រូវទ័ពខ្មែរវាយបាក់ទ័ព ហើយដេញតាមប្រកិត ។ ក្នុងឱកាសនោះ ព្រះអង្គនន់និងទ័ពខ្មែរបានដណ្តើមបានមកវិញនូវខេត្តលង់ហោរ (វិញឡុង) និងពាមមេ-ស (មីថរ) ។ ព្រះអង្គនន់ទ្រង់លើកទឹកចិត្តដល់ការបះបោររបស់ខ្មែរ ហើយទ្រង់បានរៀបចំឲ្យគេសម្លាប់ដំរីវង្គាលនូវជនជាតិអណ្តាមទាំងអស់ដែលរស់នៅលើរដ្ឋទាំងឡាយរបស់ព្រះអង្គថែមទៀតផង ។ ប៉ុន្តែឧបរាជ ព្រះឧទ័យសុរិយា និងឧបរាជធម្ម (អង្គតន់) បានរារាំងនិងធ្វើឲ្យខូចខាតផែនការនេះអស់ (អា. ឡឺក្លែរ ទំព័រ៣៩០) ។

នៅក្នុងឆ្នាំ១៨៥៧ ព្រះបាទអង្គឌួង ព្រះចៅប្រទេសកម្ពុជាបានសុំតាមរយៈម៉ុងសេញ៉រម៊ីស (Monseigneur Miche) ឲ្យព្រះចៅអធិរាជបារាំងណាប៉ូឡេអុងទី៣ បញ្ជូនទ័ពបារាំងមកវាយដណ្តើមយកព្រៃនគរឲ្យខ្មែរ ។ ព្រះបាទអង្គឌួងបានសន្យាថានឹងប្រទានប្រាក់៥០០ណែនជាសគុណ បើកាលណាបារាំងវាយឈ្នះយកទីក្រុង

នេះបានមកឲ្យខ្មែរវិញ ។

ប្លង់វាយប្រហារនេះ បានរៀបចំឲ្យកងទ័ពខ្មែរវាយប្រហារខេត្តទ្រាំងត្រើយខាងត្បូងទន្លេបាសាក់ (សុកទ្រាំង), ព្រះត្រពាំង (ត្រាវិញ), ក្រមួន-ស (រ៉ាច់យ៉ា), មាត់ជ្រូក (ចូដុក) (សូមអានព្រះរាជពង្សាវតាដំកល់នៅព្រះរាជវាំង ទំព័រ៧៥៥ (Annales déposées au Palais Roral page 755) ។

លុះមកដល់ឆ្នាំ១៨៥៨ កងទ័ពបារាំងក្រោមបញ្ជាការរបស់ឧត្តមសេនីយ៍ ឌូដាត៌ ដឺឡាហ្គ្រេ (Doudart de Lagrée) បានវាយប្រហារក្រុងព្រៃនគរ ស្របពេលគ្នានឹងការវាយប្រហាររបស់ទ័ពខ្មែរទៅលើខេត្តទ្រាំងត្រើយខាងត្បូងទន្លេបាសាក់ ព្រះត្រពាំង ក្រមួនស និងមាត់ជ្រូក (ព្រះរាជពង្សាវតាដំកល់នៅព្រះរាជវាំង ទំព័រ៧៦០ ( Annales déposées au Palais Royal page 760 et A. Leclère p.447 ) ។

ប៉ុន្តែជាអកុសល ពួកចាមដែលបះបោរនៅត្បូងឃ្មុំ ក្នុងខេត្តកំពង់ចាម បានរត់ចូលទៅក្នុងខេត្តនៅកម្ពុជាក្រោម ដោយសារជនរួមឈាមរបស់វាមកពីមាត់ជ្រូក (ចូដុក) ជួយរំដោះ ។ មហាក្សត្ររបស់យើង ពីព្រះបាទសម្តេចហរិរក្សរាមាព្រះអង្គឌួង បានព្រមានឲ្យចៅហ្វាយខេត្តយួននៅមាត់ជ្រូក ប្រគល់ចាមបះបោរទាំងនោះមកខ្មែរវិញ ។ យួនបដិសេធ ព្រះអង្គឌួងបានបញ្ជាលោកឧកញ៉ាកែប ចៅហ្វាយខេត្តទ្រាំងលើកទ័ពទៅវាយប្រហារខេត្តមាត់ជ្រូក (ចូដុក) ជាបន្ទាន់ ។ ពួកយួនអណ្ណាមនិងសម្ព័ន្ធមិត្តរបស់វា គឺពួកចាមបះបោររត់ទៅជ្រកនៅទីនោះ រៀបចំការវាយតបទប់ទ័ពខ្មែរ ប៉ុន្តែត្រូវបរាជ័យហើយដកថយ ជាឱកាសហុចឲ្យទ័ពខ្មែរលើកព្យុហយាត្រាចូលជ្រៅទៅៗក្នុងប្រទេសយួន ។ គឺក្នុងពេលនោះហើយ ដែលយួនអណ្ណាមនិងចាមលង់ទ្រនេសបរាជ័យហិនហោចដល់បន្ទូក ។ តែក្រោយពីបារាំងដណ្តើមបានទូរ៉ាន (Tourane) នៅថ្ងៃទី១កញ្ញា១៨៥៨ នឹងក្រុងព្រៃនគរនៅថ្ងៃទី១៧កុម្ភៈ១៨៥៩មក ព្រះបាទអង្គឌួងឈ្វេងយល់ថា គួរតែផ្អាកការវាយដណ្តើមដីកម្ពុជាក្រោមសិន (កូសាំងស៊ីន) ។ ព្រះអង្គឌួងទ្រង់ចូលសុវណ្ណកោដ្ឋនៅគ.ស.១៨៦០ (អា. ឡឺក្លែរ ទំព័រ៤៤៦) ។

## ~២~

## ការល្បងដណ្តើមវិញ
## រៀបចំឡើងដោយប្រជារាស្ត្រកូសាំងស៊ីន

នៅក្នុងរជ្ជកាលរបស់ស្តេចធម្មោរាជាអង្គស្ងួ (ឆ្នាំ១៧៣៨ដល់ឆ្នាំ១៧៤៧) មាន

ការវាយប្រហារមួយរវាងទ័ពខ្មែរ ដឹកនាំដោយឧកញ៉ានីរិន្ទគុកនិងពួកយួនអណ្ណាម នៅខេត្តបាសាក់ (សុកត្រាំង) ។ ពួកយួនត្រូវទទួលបរាជ័យ ដកថយទៅទៅកាន់កោះហុង នៅខេត្តពាមមេ-ស ដែលជាកោះមួយក្នុងទន្លេមេគង្គ ហើយបានធ្វើជាម្ចាស់ដីកោះនោះរហូតមក (អា. ឡឺក្លែរ ទំព័រ៣៧៥) ។

នៅក្នុងរជ្ជកាលព្រះអង្គចន្ទ (១៨០៦-១៨៣៨) នៅពេលដែលព្រះអង្គម្ចាស់អណ្ណាមង្វៀងអានបះបោរឡើងហើយប្រកាសខ្លួនជាក្សត្រប្រទេសអណ្ណាមនៅក្រុងព្រៃនគរ រួចច្បាំងជាមួយពួកតៃសឺននោះ មន្ត្រីជាន់ខ្ពស់ម្នាក់របស់ខ្មែរ ឈ្មោះឧកញ៉ាសួស បានកេណ្ឌជនរួមឈាមខ្លួននៅខេត្តព្រះត្រពាំង (ត្រាវិញ)ច្បាំងតទល់នឹងពួកយួន ។

ក្នុងរជ្ជកាលមហាក្សត្រីយានីអង្គម៉ី (១៨៣៤-១៨៤១) ដោយទ្រាំទ្រចំពោះអំពើសង្កត់សង្កិន ធ្វើបាប នៃមេទ័ពយួនឈ្មោះទ្រឿង-មិញយ៉ាង ព្រមទាំងមន្ត្រីរាជការខេត្តនានារបស់វាពុំបាន និងក្រោយពីដឹងថា យួនប៉ុនប៉ងបង្កាត់ទាំងខ្មែរលើ ទាំងខ្មែរក្រោមឲ្យទៅជាយួន ដោយពួកមហាចោរនេះបានលុបចំបាត់ដោយថោកទាបបំផុតនូវទំនៀមទម្លាប់ប្រពៃណីខ្មែរ ចៅហ្វាយស្រុកព្រះត្រពាំងម្នាក់ ឈ្មោះចៅហ្វាយគុយ បានដឹកនាំជនរួមជាតិរបស់ខ្លួនឲ្យក្រោកបះបោរតវ៉ាឡើង ។ លោកចៅហ្វាយស្រុកគុយ បានធ្វើ«ទុក្ខកិរិយា»សម្លាប់ខ្លួនដោយសោកនាដ្យកម្ម ដើម្បីដឹកនាំចលនាតស៊ូយ៉ាងប្តូរផ្តាច់ ក្នុងបំណងឲ្យយួនទុកឲ្យខ្មែរវិញ នូវប្រពៃណីខ្មែរនិងសាសនារបស់ខ្មែរ ។ ការតស៊ូនិងការទាមទារនេះ បានក្លាយមកជាប្រពៃណីនិងជាកាតព្វកិច្ចខ្មែរកម្ពុជាក្រោម (កូសាំងស៊ីន) រហូតមកដល់សព្វថ្ងៃ ។

នៅឆ្នាំ១៨៤៧ គឺក្នុងពេលព្រះអង្គឌួងទើបនឹងឡើងគ្រប់គ្រងរាជសម្បត្តិ (១៨៤៧-១៨៥៩) មេទ័ពខ្មែរម្នាក់ឈ្មោះ ឡោមសោម ដែលគេហៅរត់មាត់ថា តាសោម (Lom Som) បានក្រោកឡើងដឹកនាំការបះបោរនៅក្នុងស្រុកទាបភ្លើង (តំបន់កន់ចុង) ខេត្តព្រះត្រពាំង (ត្រាវិញ) ដើម្បីសងសឹកយួនចំពោះមរណភាពរបស់ចៅហ្វាយគុយ ជាពិសេសដើម្បីធ្វើការតស៊ូដេញកំចាត់យួនអណ្ណាមចេញពីដីខ្មែរ ក្នុងបំណងដណ្តើមយកដីមរតកដូនតាមកវិញ ។ ដោយមានជំនួយពីមេទ័ពរងរបស់ខ្លួនឈ្មោះសេនាឯកប្រោញ និងលោកមឿងសោម ព្រមទាំងអាជ្ញាធរខ្មែរនៅក្នុងខេត្តនោះគាំទ្រផង លោកឡោមសោមបានវាយឈ្នះយួន ហើយលើកទ័ពចូលរហូតដល់តំបន់ផ្នូដោង (Phno Dong) ក្នុងខេត្តព្រះត្រពាំងដដែល ហើយបានបញ្ជាឲ្យសម្លាប់រង្គាលនូវយួនអណ្ណាមទាំងឡាយនិងអុងបូរ ចៅហ្វាយខេត្តរបស់វាផង ។ ប៉ុន្តែបន្ទាប់មក ទ័ពលោកឡោមសោមត្រូវបរាជ័យ ដោយយួនបានបញ្ជូនទ័ពជំនួយយ៉ាងច្រើនទៀត មកពីខេត្តខាងកើត ដើម្បីទប់ដំណើរនិងវាយប្រហារទ័ពខ្មែរ ។ យួន

បានចាប់មេទ័ពឡោមសោម ដាក់ទ្រុងបញ្ជូនទៅក្រុងវេ ហើយត្រូវស្តេចយួនឈ្មោះ ធីវទ្រី (Thiev-Tri) បញ្ជាឲ្យសម្លាប់ចោល (អញ្ជើញអានសៀវភៅកូសាំងស៊ីន, ១៩-៣០ ទំព័រ២២ និងរឿងនិទានលើថ្ម) ។

នៅឆ្នាំ១៨៥៦ ពួកយួនអណ្ណាមបានស្ថាបនាបន្ទាយយ៉ាងធំនៅបាយសូរ (Bai Xou) សុកទ្រាំង (ទីរួមខេត្ត) និងនៅញូយ៉ា (Nhu Gia) ក្នុងបំណងធ្វើការវាតដីចុះចុះមកខាងលិចផង និងពង្រឹងស្ថានភាពរបស់យួនផង ។ ពួកយួនបានព្រមានលោកចៅហ្វាយស្រុកសុកឲ្យចុះចូលវា ប៉ុន្តែផ្ទុយទៅវិញ ចៅហ្វាយស្រុកសុកនិងខ្មែរបានក្រោកឡើងដោយមានលោកសេនាលឹមនៅបាសាក់ជាអ្នកដឹកនាំប្រឆាំងហើយសម្លាប់រង្គាលនូវយួនអណ្ណាមគ្រប់ប្រភេទ នៅក្នុងតំបន់ទំនប់និងកំពង់ត្រប់ ដែលសព្វថ្ងៃយួនហៅថា «ទួនវ៉ា» (Thuan Hoa) នៅក្នុងខេត្តសុកទ្រាំង ។

នៅឆ្នាំ១៨៥៩ យួនអណ្ណាមបានរៀបចំជាថ្មីទៀត ព្រមទាំងអន្ទងចាមនៅខេត្តមាត់ជ្រូក (ចូដុក) ឲ្យចូលជួយច្បាំងវាផង ។ ខ្មែរបានផ្តើមប្រតិបត្តិការសឹកជាថ្មីឡើងទៀត ។ លោកសេនាសួសព្រមទាំងរេហ៍ពលរបស់លោក បានរៀបចំទ័ពខ្មែរលើកទៅបង្ក្រាបយួនអណ្ណាមនៅមហាទុប (យួនហៅថាវ៉ាទួន Hoathuan) និងចុងបាឡាង (អាននិញ) ក្នុងខេត្តសុកទ្រាំង ។ នៅក្នុងកំឡុងពេល៣ឆ្នាំ ទ័ពខ្មែរបានប្រយុទ្ធគ្នាឥតឈប់ ប្រកបដោយជោគជ័យ សម្លាប់យួនអស់ជាច្រើន នៅក្នុងចំណោមនោះមានឧត្តមមេបញ្ជាការយួនពីរនាក់ផង ឈ្មោះអុងឡាន់សម (Ong Lanh Sam) និងអុងឡាន់ប៊ិនស៊ី (Ong Lanh Binh Si) ដែលមានផ្នូរនៅសុកទ្រាំសព្វថ្ងៃជាអនុស្សាវរីយ៍ស្រាប់ ។ តែលោកសេនាសួស ត្រូវពួកចាមដែលជាសម្ព័ន្ធមិត្តយួនអណ្ណាមបំពុលស្លាប់ក្នុងពេលជាខាងក្រោយមក (រឿងនិទានសរសេរលើថ្ម) ។

នៅឆ្នាំ១៨៦០ បងប្អូន២នាក់ឈ្មោះសេនាទា និងសេនាមាន់ បានក្រោកឡើងបះបោរនៅឡោមពួយ (Lom Pouyea) ប៉ុន្តែត្រូវបង្ខំចិត្តដកទ័ពទៅកាន់បាក់លីវ ក្នុងតំបន់ត្រខា (Tra Kha) ក្នុងភូមិឡុងថាន់សព្វថ្ងៃ ដោយពុំអាចទ្រាំទ្រនឹងយួនដែលមានទ័ពច្រើនលើសលប់បាន ។ ក្រោយមកសេនាទា សេនាមាន់ បានច្បាំងឈ្នះយួនវិញ ហើយលើកទ័ពដេញយួនរហូតដល់ពាមប៉ូលីវ (Péam Poliêv) ។ នៅទីនោះយួនបានទទួលជំនួយទ័ពចាមយ៉ាងច្រើន ហើយសេនាទាត្រូវទ័ពខ្មែរដឹកនាំយកទៅបញ្ចុះនៅក្នុងកូនកោះមួយ នៅក្បែរវត្តខ្មែរមួយនៅខ្វែងបូបិល (Khveng Bobel) ក្នុងភូមិប្អូនហៅហ៊ុំងហួយ នៃខេត្តបាក់លីវ ។

□

# ~៣~

# ការទាមទារថ្មីមួយ
# របស់ព្រះបាទអង្គឌួង និង ព្រះបាទនរោត្តម

យើងបានឃើញនៅក្នុងវគ្គខាងលើ ស្តីពីការល្បងដណ្តើមដីវិញ ដែលព្រះបាទ សម្តេចហរិរក្សរាមាព្រះអង្គឌួងបានរៀបចំឡើងនៅកម្ពុជាក្រោម (កូសាំងស៊ីន)ស្រេចអស់ហើយ ក្នុងគោលបំណងដេញយួនអណ្តាមចេញពីរដ្ឋទាំងឡាយរបស់ព្រះអង្គ ។ ថ្វីបើព្រះអង្គជាក្សត្រធម៌ករុណានិងស្រឡាញ់សន្តិភាព ដោយហេតុអាណាប្រជានុរាស្ត្ររបស់ព្រះអង្គរងទុក្ខវេទនាមិនចេះចប់ក្តី ក៏ព្រះអង្គឌួងពុំអាចនៅព្រងើយកន្តើយចំពោះទុក្ខវេទនារបស់ប្រជារាស្ត្រព្រះអង្គ នៅប៉ែកខាងក្រោមដែលរងការសង្កត់សង្កិនបានដែរ ។ ព្រះអង្គទ្រង់បានត្រាស់បង្គាប់ឲ្យកសាងបន្ទាយយ៉ាងធំនៅក្នុងខេត្តមាត់ជ្រូក (ចូដុក) និងពាមឬមួងខាំ (ហាទៀង) ដែលទុកដូចជាបន្ទាយមុខនៃការតស៊ូរបស់ខ្មែរ ។ ដោយសព្វព្រះទ័យម៉្យាងនឹងជោគជ័យដំបូងទាំងឡាយរបស់ព្រះអង្គ និងដោយឃើញបរាជ័យបន្តបន្ទាប់គ្នារបស់យួនអណ្តាម ព្រះបាទអង្គឌួងបានទៅដល់ទីដៅយ៉ាងប្រាកដណាស់ ហើយពិតជានឹងបានជាសម្ព័ន្ធមិត្តដ៏ប្រាកដមួយរបស់ប្រទេសបារាំង ក្នុងការប្រឆាំងប្រទេសអណ្តាម បំណងដណ្តើមយកដីសំបូរជីរជាតិរបស់ព្រះអង្គ ដែលយួនលួចយកទៅ បើសិនណាហើយព្រះអង្គពុំបានប្រឈួនរួចចូលសុវណ្ណកោដ្ឋនៅក្នុងឆ្នាំ១៨៦០ ដែលជាហេតុមួយធ្វើឲ្យផែនការរបស់ព្រះអង្គចប់ទៅនោះ (អញ្ជើញអានសៀវភៅរបស់លោក អាដេម៉ាដ៏ឡឺក្លែរ ពីទំព័រ ៤៤៥ដល់៤៤៧ **A. Leclère pp.445-447**) ។

ក្រៅពីចំបាំងទាំងឡាយដឹកនាំផ្ទាល់ព្រះអង្គប្រឆាំងនឹងយួនអណ្តាម និងការសុំជំនួយនិងកិច្ចគាំទ្រផ្សេងៗពីព្រះចៅណាប៉ូឡេអុងទី៣ អធិរាជប្រទេសបារាំងនោះ ព្រះបាទអង្គឌួងទ្រង់បានផ្ញើចុតហ្មាយយ៉ាងច្រើនទៅទូលអធិរាជអង្គនេះ ឲ្យជ្រាបអំពីសិទ្ធិលើទឹកដីនានារបស់ខ្មែរនៅកម្ពុជាក្រោម (ដែលយួននិងបារាំងហៅថាកូសាំងស៊ីន) ។ នៅខែវិច្ឆិកា១៨៥៥ ព្រះបាទអង្គឌួងបានសុំ (ម៉ុងសេញ៉័រមីស) សរសេរចុតហ្មាយមួយ ផ្ញើទៅចងស្ពានមេត្រីជាមួយព្រះចៅណាប៉ូឡេអុងទី៣ ។ ចុតហ្មាយនោះបានផ្ញើទៅប្រទេសបារាំង តាមរយៈកុងស៊ុលបារាំងនៅសឹង្ហបុរី ដោយមានទាំងដង្វាយ (ស្នួយសា) មួយហិបផង ។

ប៉ុន្តែក្នុងពេលលោកដឺម៉ុងទីញីអញ្ជើញមកដល់ប្រទេសកម្ពុជា ស្រាប់តែព្រះបាទអង្គឌួងភ្ញាក់ព្រះអង្គ ដោយលោកដឺម៉ុងទីញីទូលថា គេឥតបានទទួលឬដឹងដំ–